## ១. បញ្ហានានាដែលកើតមានក្នុងអត្ថបទច្បាប់

មានបញ្ហាមួយចំនួន ស្ថិតនៅក្នុងអត្ថបទនៃច្បាប់ការងារនេះ ដែលបង្កជាការលំបាកដល់ការបកស្រាយផង និងការអនុវត្តន៏ផង ។ បញ្ហាចម្បងៗ ដែលយើងអាចឃើញនៅក្នុងច្បាប់នេះរួមមាន :

- បទប្បញ្ញត្តិដែលទាក់ទងដល់ទិដ្ឋភាពផ្សេងៗនៃប្រាក់កំរៃ/ប្រាក់ឈ្នួល
- ភាពមិនច្បាស់លាស់ក្នុងមាត្រា ១៣ ដែលទាក់ទងទៅនឹងការអនុវត្តន៏តាមស្តង់ដាអប្បរមានៃច្បាប់នេះ
- បដិបញ្ញត្តិទាក់ទងទៅនឹងការកាត់ប្រាក់ឈ្នួលរបស់និយោជក សំរាប់ការបង់ភាគទានទៅសហជីព និង
- ភាពមិនច្បាស់លាស់នៃភាសាបច្ចេកទេសក្នុងច្បាប់ (ដូចជាៈ ខ ប្រការ បញ្ញត្តិ មាត្រា ជាដើម ។ល។)

ផ្នែកឧបសម្ព័ន្ធនៃរបាយការណ៏នេះ មានរៀបរាប់លំអិតអំពីការប្រៀបធៀបមាត្រានានា នៅក្នុងច្បាប់នេះពាក់ព័ន្ធទៅនឹងប្រធានបទតែមួយ ដែលមិនមានភាពច្បាស់លាស់ ឬដែលបញ្ច្រាសគ្នា។

### ក. ភាពមិនស៊ីសង្វាក់គ្នាក្នុងការប្រើពាក្យពេចន៍

មាត្រា ១០២ និង ១០៣ នៃច្បាប់នេះបានផ្តល់និយមន័យនៃពាក្យ "ប្រាក់ឈ្នួល" ដូចខាងក្រោម :

*... ពាក្យថា ប្រាក់ឈ្នួល ទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយមានន័យថា ឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកំរិតបានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឱ្យកម្មករនិយោជិតតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្តី ឬដែលត្រូវធ្វើក្តី ...*

*ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ : ប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ម៉ោងបន្ថែម កំរៃជើងសារ បុព្វលាភ និង ប្រាក់បំណាច់ ភាគកម្មក្នុងប្រាក់ចំណេញ ប្រាក់ដែលបើកជារង្វាន់ តម្លៃអត្ថប្រយោជន៍ជាវត្ថុ វិភាជន៍គ្រួសារសំរាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ វិភាជន៍សំរាប់ការឈប់សំរាក ឬបំណាច់សំរាប់ទូទាត់ការឈប់សំរាក ចំនួនប្រាក់ដែលនិយោជកត្រូវផ្តល់ឱ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្ម និងពេលលំហែមាតុភាព ...*

ច្បាប់មិនបានឆ្លុះបញ្ចាំងឱ្យស្របទៅនឹងនិយមន័យនៅក្នុងមាត្រា ១០៣ នេះទេ។ មានមាត្រាជាច្រើនបានរាប់បញ្ចូលបន្ថែមនូវពាក្យ "ប្រាក់ឈ្នួល" ទៅក្នុងធាតុផ្សេងៗនៃប្រាក់ឈ្នួល ទៅលើនិយមន័យក្នុងមាត្រា ១០៣ នេះ (សូមអានឧបសម្ព័ន្ធ)។ ឧទាហរណ៍ ក្នុងមាត្រា ១៦៨ ដែលទាក់ទងនៅនឹងប្រាក់វិភាជន៍ក្នុងពេលឈប់សំរាកប្រចាំឆ្នាំ ដែលប្រាក់វិភាជន៍នេះត្រូវធ្វើការគណនាស្មើនឹង *"ចំនួនមធ្យមនៃប្រាក់បុព្វលាភ វិភាជន៍ អត្ថប្រយោជន៍ បំណាច់ គិតទាំងតម្លៃវត្ថុដែលផ្តល់ផង ..."*។ ចំណុចនេះបញ្ជាក់ឱ្យឃើញថា ធាតុនានានៃប្រាក់ឈ្នួលរួមមាន: ប្រាក់វិភាជន៍ អត្ថ-ប្រយោជន៍ បំណាច់ គិតទាំងតម្លៃវត្ថុដែលផ្តល់ផង ដែលនេះមិនបានរាប់បញ្ចូលថាជា "ប្រាក់ឈ្នួល" នៅក្នុងមាត្រានោះឡើយ។

ការចែងយ៉ាងដូច្នេះ នាំឱ្យអ្នកអនុវត្តច្បាប់នេះមានការយល់ច្រឡំ ហើយបានបណ្តាលឱ្យមានវិវាទជាច្រើននៅតាមរោងចក្រនានា ដែលវិវាទមួយចំនួនធ្ងន់ធ្ងរហួសត្រូវនាំទៅជំរះសេចក្តីនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល (សូមអានរឿងក្តី លេខ ២៤/០៣ ស្តីពី ថបវ័ន្ត រឿងក្តីលេខ ៤៩/០៤ ស្តីពី ហូហ៊ីង រឿងក្តីលេខ ៦៨/០៤ ស្តីពី ស៊ីធីញូវ)។ ខណៈដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការតាក់តែងនូវយុត្តិសាស្ត្រ ទៅលើភាពមិនស៊ីសង្វាក់គ្នាទាំងនេះ (សូមអានឧបសម្ព័ន្ធ) យើងអាចឃើញយ៉ាងច្បាស់ថា ច្បាប់ការងារគួរតែផ្តល់និយមន័យមួយជាក់លាក់ ដែលអាចយកទៅអនុវត្តបានគ្រប់មាត្រានៃច្បាប់ទាំងមូលដែលផ្តល់នូវកាតព្វកិច្ចតាមផ្លូវច្បាប់ ពាក់ព័ន្ធដល់ប្រាក់កំរៃ/ប្រាក់ឈ្នួល នេះ។

### ខ. កម្មករនិយោជិតម្តងម្កាល និង ជាប់លាប់

ច្បាប់នេះបានចែងដាច់ពីគ្នានូវការងារម្តងម្កាល និង ជាប់លាប់។ មាត្រា ៩ នៃច្បាប់នេះបានផ្តល់និយមន័យដល់កម្មករនិយោជិតម្តងម្កាល និង ជាប់លាប់ ដូចខាងក្រោម :

*...កម្មករនិយោជិតជាប់លាប់គឺជនដែលធ្វើការទៀងទាត់ក្នុងមុខការអ្វីមួយដែលមានលក្ខណៈជាអចិន្ត្រៃយ៍។*

*កម្មករនិយោជិតម្តងម្កាល គឺជនដែលចុះកិច្ចសន្យា :*

*- ធ្វើការមួយជាប្រាកដ តាមធម្មតាត្រូវតែឱ្យហើយក្នុងរយៈពេលយ៉ាងខ្លី។*



*- ធ្វើការមួយពេលៗ ធ្វើឈប់ៗ និងធ្វើមួយរដូវៗ។*

មាត្រា ១០ នៃច្បាប់នេះបានចែងថា : *"កម្មករនិយោជិតម្តងម្កាល ត្រូវប្រតិបត្តិនូវវិធាន និងកាតព្វកិច្ចដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ ហើយក៏មានសិទ្ធិដូចគ្នាដែរ លើកលែងតែកាលណាមានខសន្យាដោយឡែកពីនេះ"*។ មាន ខ ប្រការតិចតួចដែលចែងពីភាពខុសគ្នារវាងកម្មករនិយោជិតពីរប្រភេទនេះ (សូមអានឧបសម្ព័ន្ធ)។ ដោយសារតែមានការចែងកំណត់ដាច់ដោយឡែកពីគ្នាបែបនេះ ទើបមាត្រា១០ កំណត់អំពីលក្ខណៈដោយឡែករវាងប្រភេទការងារទាំងពីរនេះ។ ជាលក្ខណៈអន្តរជាតិ ការងារម្តងម្កាលគឺជាការរៀបចំក្នុងលក្ខខណ្ឌដែលអាចបត់បែនបានរវាងកម្មករ-និយោជិត និងនិយោជក នៅក្នុងក្របខណ្ឌដែលច្បាប់ផ្តល់សិទ្ធិឱ្យ។ ឧទាហរណ៍ កម្មករម្តងម្កាលម្នាក់អាចនឹងមិនទទួលបានប្រាក់វិភាជន៍ឈប់សំរាកប្រចាំឆ្នាំទេ តែការបាត់បង់នូវអត្ថប្រយោជន៍នេះ គាត់អាចទទួលបានមកវិញតាមរយៈការទទួលប្រាក់ឈ្នួលលើសពីអត្រាប្រចាំម៉ោងធម្មតា ឬក៏ការតម្រូវឱ្យជូនដំណឹងមុនអាចនឹងមិនយកអនុវត្តចំពោះកម្មករនិយោជិត ឬ កម្មករនិយោជិតនៅក្នុងទំនាក់ទំនងការងារម្តងម្កាលនេះ។ មាត្រា ១០ ដូចជាមិនបានរាប់បញ្ចូលនូវភាពបត់បែននេះ ក្នុងគោលបំណងដើម្បីធ្វើឱ្យការបែងចែកដាច់ពីគ្នានៃទំរង់ការងារទាំងពីរនេះ ក្នុងមាត្រា ៩ កាន់តែមានភាពសម្បូរបែបឡើង។

ច្បាប់នេះមិនបានចែងច្បាស់ នូវគោលបំណងពិតប្រាកដក្នុងការផ្តល់នូវភាពបត់បែននេះនៅក្នុងការអនុវត្តន៍ជាក់ស្តែងនៃការងារឡើយ។ បើសិនមិនអនុញ្ញាតឱ្យមានលក្ខណៈដាច់ពីគ្នានោះទេ ការបែងចែកបែបនេះកាន់តែ ធ្វើឱ្យមានភាពច្របូកច្របល់ដល់កម្មករនិយោជិត ក៏ដូចជានិយោជកដែរ ហើយនឹងនាំមកនូវវិវាទការងារដែលមិនចាំបាច់ផងដែរ (សូមអានរឿងក្តីលេខ ៣០/០៤ ស្តីពី ហានី វ៉ែរ រឿងក្តីលេខ ៧៨/០៤ ស្តីពី អេអាយអេ រឿងក្តីលេខ ៨៥/០៤ ស្តីពី កាង នីង)។

### គ. សិទ្ធិ និង ប្រយោជន៍ដែលត្រូវទទួលបាននៅក្នុងការងារ

ច្បាប់នេះបានកំណត់ថា រាល់ទំនាក់ទំនងក្នុងការងារត្រូវតែអនុលោមទៅតាមច្បាប់នេះតែមួយគត់ គឺច្បាប់ការងារ និងកិច្ចសន្យាការងារបុគ្គលទោះបីជាលាយលក្ខណ៍អក្សរក្តី ឬ ដោយផ្ទាល់មាត់ក្តី ឬ ច្បាប់ការងារ និងអនុ-សញ្ញារួម (CBA) ណាមួយ។ រាល់កិច្ចសន្យាជាលក្ខណៈបុគ្គល និងអនុសញ្ញារួម អាចនឹងធ្វើឡើងជាលក្ខខណ្ឌការងារមួយ ឬអាចនឹងត្រូវធ្វើការចរចារវាងនិយោជក និងកម្មករនិយោជិតក្នុងពេលមានទំនាក់ទំនងក្នុងការងារ។ ច្បាប់នេះក៏បានបង្កើតជាសិទ្ធិ ផលប្រយោជន៍ និងកាតព្វកិច្ចដល់និយោជក និងកម្មករនិយោជិត នៅកម្ពុជា។ ការផ្តល់អំណាចដែលមានចែងក្នុងច្បាប់នេះ គឺជាការផ្តល់អំណាចកំរិតអប្បរមា ដែលផ្តល់ដោយមាត្រា ១៣ នៃច្បាប់ការងារ ដូចខាងក្រោម :

*បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារនេះ មានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ វៀរលែងតែមានបដិប្បញ្ញត្តិបញ្ជាក់ច្បាស់។ ដូច្នេះវិធានទាំងអស់ដែលកើតឡើងដោយការសំរេចចិត្តជាឯកតោភាគីក្តី ដោយកិច្ចសន្យា ឬអនុសញ្ញាណាមួយក្តីដែលមិនគោរពបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬដែលមិនគោរពអត្ថបទទាំងឡាយ ដែលណែនាំអនុវត្តច្បាប់នេះ ត្រូវទុកជាមោឃៈដោយពេញច្បាប់ ...*

ផ្ទុយទៅវិញ បើយោលទៅលើទំរង់នៃការរៀបចំកិច្ចសន្យាការងារ និងការចរចាអនុសញ្ញារួម និងកិច្ចព្រមព្រៀងក្នុងការផ្សះផ្សាក្តី ច្បាប់នេះមិនបានផ្តល់អំណាចឱ្យបានច្បាស់លាស់ ដោយមិនបានចែងអំពីអត្ថប្រយោជន៍ និងសិទ្ធិសំខាន់ៗដែលគួរតែមានក្នុងច្បាប់នេះឡើយ ( សូមអាន ឧបសម្ព័ន្ធ ) ។

ជាងនេះទៅទៀត ក៏មានភាពស្រពិចស្រពិលផងដែរ នៅក្នុងទិដ្ឋភាពនៃលក្ខខណ្ឌនានា គួរមាននៅក្នុងកិច្ចសន្យា ឬ អនុសញ្ញារួម ថាតើវាស្ថិតនៅទាបជាងអ្វីដែលច្បាប់បានបដិសេធ ឬយ៉ាងណា មានដូចជា:

(១) ទិដ្ឋភាពរួមនៅក្នុងកិច្ចសន្យា ឬ អនុសញ្ញារួម

(២) បទប្បញ្ញត្តិជាក់លាក់នៅក្នុងកិច្ចសន្យា ឬ អនុសញ្ញារួម ដែលនៅទាបជាងការកំណត់របស់ច្បាប់

(៣) វិធានពិសេស ដែលកើតចេញពីការអនុវត្តន៍បទប្បញ្ញត្តិ ទៅតាមបរិបទនៃហេតុការណ៍ជាក់លាក់ណាមួយ ( មានន័យថា ដែលអាស្រ័យទៅលើបរិបទដែលបទប្បញ្ញត្តិនោះអាចមាន ទោះបីវាស្ថិតនៅខ្ពស់ជាងប្រសិទ្ធភាពនៃច្បាប់ ឬនៅទាបជាងប្រសិទ្ធភាពនៃច្បាប់ក៏ដោយ តែប្រសិនបើវាមានកំរិតទាបជាងប្រសិទ្ធភាពនៃច្បាប់ គេអាចទុកជាមោឃៈមិនខាន) ( សូមអានឧបសម្ព័ន្ធ ) ។

ដោយហេតុនេះ នាពេលបច្ចុប្បន្នមានអនុសញ្ញារួមតិចតួចណាស់នៅកម្ពុជា ការកាត់បន្ថយនូវកំរិតប្រសិទ្ធភាពនៃភាពមិនច្បាស់លាស់ នៅក្នុងមាត្រានេះ គឺក្នុងគោលបំណងលើកស្ទួយឱ្យមានអនុសញ្ញារួមមួយដែលអាចជឿជាក់បាននោះ បញ្ហាអស់ទាំងនេះគួរតែត្រូវបញ្ជាក់ឱ្យបានច្បាស់ ។

## ២. ដែនអនុវត្តន៍ច្បាប់ការងារ

មាត្រា ១ នៃច្បាប់នេះបានចែងថា :

*ច្បាប់នេះ គ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត ដើម្បីយកមកអនុវត្តន៍លើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះបី ភាគីទាំងនោះមានសញ្ជាតិជាអ្វី ហើយស្នាក់នៅទីណាក៏ដោយ ...*

ច្បាប់នេះក៏បានចែងផងដែរអំពីប្រភេទកម្មករនិយោជិតមួយចំនួន ដែលស្ថិតនៅក្រៅដែនអនុវត្តន៍ ។ ប្រភពកម្មករនិយោជិតទាំងនោះរួមមាន មន្ត្រីរាជការ ចៅក្រម មន្ត្រីនគរបាល និងយោធា បុគ្គលិកផ្នែកដឹកជញ្ជូន ទាំងផ្លូវអាកាស និង ផ្លូវសមុទ្រ ឬអ្នកធ្វើការតាមផ្ទះ ជាដើម ។

បើតាមទិដ្ឋភាពច្បាប់នេះ នៅមានភាពមិនច្បាស់លាស់ត្រង់ថា ហេតុអ្វីក៏ប្រភេទកម្មករខ្លះ ដែលជានិយោជិតដែរ តែមិនបានរាប់បញ្ចូលនៅក្នុងច្បាប់នេះ ។ ដើម្បីធានាឱ្យបាននូវភាពស៊ីសង្វាក់គ្នា ការទទួលបាននូវអត្ថប្រយោជន៍ សិទ្ធិ និងការផ្តល់អំណាចស្មើគ្នា ដែនអនុវត្តន៍នៃច្បាប់ការងារនេះ គួរតែពង្រីកដោយរាប់បញ្ចូលទាំងទំនាក់ទំនងរវាងនិយោជក និង និយោជិតទាំងអស់ ដែលកើតចេញពីកិច្ចសន្យាការងារផងដែរ ( ទោះបី ជាលាយលក្ខណ៍អក្សរក្តី ឬដែលមានកំណត់ក្នុងច្បាប់ក្តី) ដែលបានធ្វើឡើងនៅកម្ពុជា ជាជាងចែងអំពី អ្វីដែលបង្ហាញអំពីការមិនរាប់បញ្ចូលនាំឱ្យមាន ដែលមិនស្របច្បាប់ ។



## ៣. អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

នាពេលបច្ចុប្បន្ននេះ អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានកំណត់ទៅលើត្រឹមតែ វិវាទរួមប៉ុណ្ណោះ រីឯវិវាទបុគ្គលត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការ ( ដោយមិនទាន់មានបង្កើតតុលាការការងារនៅឡើយទេ ) ។

ចាប់តាំងពេលការបង្កើតនា ឆ្នាំ ២០០៣ មកដល់ពេលបច្ចុប្បន្ននេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្ថិតនៅជាស្ថាប័នយុត្តិធម៌តែមួយគត់នៅក្នុងប្រទេស ចំណែកឯប្រព័ន្ធពង្រឹងច្បាប់ និង តុលាការ ត្រូវបានគេចាត់ទុកថាខ្វះភាពអព្យាក្រឹត មិនឯករាជ្យ និង កង្វះវិជ្ជាជីវៈច្បាស់លាស់ ។ ក្រោមគំនិតផ្តួចផ្តើមនៃ ***គំរោងដោះស្រាយវិវាទការងារ*** របស់អង្គការពលកម្មអន្តរជាតិ (*Labour Dispute Resolution Program* ILO) ក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺជាស្ថាប័នឯករាជ្យ ដែលបង្កើតឡើងដើម្បីដោះស្រាយវិវាទការងាររួមតាមរយៈ ការផ្សះផ្សា ការបើកសវនការ និងការចេញសេចក្តីបង្គាប់ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នអាជ្ញាកណ្តាលដំបូងនៅកម្ពុជា ហើយដែលត្រូវបានគេចាត់ទុកថា ជាកំណត់សម្គាល់មួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងវិជ្ជាជីវៈយ៉ាងត្រឹមត្រូវនៅកម្ពុជា ព្រោះស្ថាប័ននោះមានរចនាសម្ព័ន្ធផ្លូវការមួយ ក្នុងការដោះស្រាយវិវាទការងារបានឆាប់រហ័ស និងមានប្រសិទ្ធភាពដោយឈរលើគោលការណ៍នៃការស្វែងរកហេតុផលតាមផ្លូវច្បាប់ ដោយបើកចំហជាសាធារណៈ និង ត្រឹមត្រូវផង ។

ការពង្រីកវិសាលភាពផ្នែកយុត្តាធិការរបស់ក្រុមប្រឹក្សានេះ ដោយរាប់បញ្ចូលទាំងវិវាទបុគ្គលផងនោះ នឹងផ្តល់នូវលើកស្ទួយគួរឱ្យកត់សម្គាល់ ចំពោះការទទួលបាននូវយុត្តិធម៌ ដល់បុគ្គលកម្មករនិយោជិតម្នាក់ៗ និងក៏អាចបញ្ចៀសបាននូវការពង្រីកជាបញ្ហាវិវាទបុគ្គល ទៅជាវិវាទរួមដែលមានទំហំខូចខាតធំ ។

## ៤. សន្និដ្ឋាន

ការលំបាកនានាជាច្រើននៅក្នុងច្បាប់ការងារ ដែលរបាយការណ៍បានលើកឡើងមកនេះ គឺទាក់ទងទៅនឹងភាពស្រពិចស្រពិលនៅក្នុងពាក្យពេចន៍ ដែលប្រើក្នុងច្បាប់នេះតែម្តង ។ ការកែសម្រួលយ៉ាងផ្ចិតផ្ចង់ និងដែលអាចយល់បាន ចំពោះពាក្យពេចន៍ដែលប្រើក្នុងច្បាប់នេះ អាចនឹងធានាបាននូវភាពស៊ីសង្វាក់គ្នា និងផ្តល់នូវភាពជាក់លាក់ដល់អ្នកដែលច្បាប់នេះគ្របដណ្តប់ទៅលើ និងពិសេសជាងនេះទៅទៀតគឺអ្នកអនុវត្តច្បាប់នេះតែម្តង ។ ការកែប្រែបែបនេះ គឺជាសក្តានុពលមួយ ក្នុងការកាត់បន្ថយបាននូវវិវាទការងារណាដែលមិនចាំបាច់ នៅកម្ពុជា ។

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ក៏បានជំរុញក្រសួងវិស័យការងារ និង អង្គការ ILO ក្នុងការចេញផ្សាយនូវការបកប្រែអត្ថបទច្បាប់នេះឱ្យបានត្រឹមត្រូវ ស្របទៅតាមអត្ថន័យជាភាសាខ្មែរ ។ ការបកប្រែត្រឹមត្រូវ នោះអាចនឹងយកមកប្រើជាឯកសារយោង ដែលអាចធានាឱ្យកើនឡើងនូវភាពស៊ីសង្វាក់គ្នាក្នុងការ អនុវត្តន៍ស្របទៅនឹងបញ្ញត្តិ ច្បាប់ការងារ សំរាប់គ្រប់ភាគី រួមទាំង វិនិយោគិនបរទេស ។

# "និន្នាការ និង តំរូវការនៃការកែសំរួលច្បាប់ការងារ នៅប្រទេសកម្ពុជា ~ ការរកឃើញ និង អនុសាសន៍"

## ដោយកញ្ញា អាន វីរៈ - ប្រធានផ្នែកកម្មវិធីច្បាប់ការងារនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

តារាងនេះបង្ហាញអំពីភាពមិនច្បាស់លាស់ និង មិនស្របគ្នា ទាំងក្នុងការប្រើពាក្យពេចន៍ និង ខ្លឹមសារនៃច្បាប់ នៅក្នុងអត្ថបទច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ។ ចំណុចបញ្ហាសំខាន់ៗមានដូចតទៅ:

១- ប្រភេទនៃកម្មករនិយោជិត

២- ការខ្វះខាតការបញ្ជាក់អំពីសាកល្បងការងារ

៣- បទប្បញ្ញត្តិទាក់ទងនឹងទស្សនៈខុសៗគ្នានៃប្រាក់កំរៃ/ប្រាក់ឈ្នួល

៤- ការខ្វះខាតការបញ្ជាក់នៅក្នុងមាត្រា១៣ ទាក់ទងនឹងការគោរពតាមកំរិតអប្បបរមានៃច្បាប់

៥- បទប្បញ្ញត្តិដែលមានលក្ខណៈផ្ទុយគ្នាទាក់ទងនឹងការដែលនិយោជកកាត់ប្រាក់ឈ្នួលសម្រាប់ភាគទានសហជីព

៦- ព័ត៌មានមិនពេញលេញសម្រាប់ការឈប់សំរាកដោយមានជំងឺ

៧- ការខ្វះខាតការបញ្ជាក់ឱ្យបានច្បាស់លាស់ចំពោះពាក្យពេចន៍ច្បាប់

| មាត្រា | បញ្ញត្តិ | និយមន័យ/អត្ថន័យ | ចំណុចបញ្ហា | យុត្តិសាស្ត្រ |
|---|---|---|---|---|
| **កម្មករនិយោជិតជាប់លាប់/មួងម្កាល** | | | | |
| មាត្រា ៩ | កម្មករនិយោជិតមួងម្កាល / កម្មករនិយោជិតជាប់លាប់ | កម្មករនិយោជិតជាប់លាប់គឺ<br>- ជនដែលធ្វើការទៀងទាត់ ក្នុងមុខការអ្វីមួយ ដែលមានលក្ខណៈជា អចិន្ត្រៃយ៍ ។<br>កម្មករនិយោជិតមួងម្កាលគឺជនដែលចុះកិច្ចសន្យា :<br>- ធ្វើការមួយជាប្រាកដ តាមធម្មតាត្រូវតែធ្វើឱ្យ | មានការបែងចែកច្បាស់លាស់រវាងកម្មករនិយោជិតជាប់លាប់ និងកម្មករនិយោជិតមួងម្កាល ។ តែទោះជាយ៉ាងណា បើធ្វើការបកស្រាយតាម ន័យពាក្យមាត្រា ១០បង្ហាញថាមានការខុសគ្នា ច្រើនរវាងប្រភេទការងារទាំង២ ។ | **២៦/០៤, ៥៣/០៤, ៥៥/០៤, ៨៥/០៤** (ប្រសិនបើកម្មករនិយោជិតមួងម្កាលធ្វើការលើសពី២១ថ្ងៃក្នុងមួយខែ សំរាប់រយៈពេល២ខែជាប់ៗគ្នា នោះគួរតែចាត់ទុកជាកម្មករនិយោជិតក្នុងរយៈពេលសាក |



| | | | | |
|---|---|---|---|---|
| មាត្រា ១០ | | ហើយក្នុងរយៈពេលយ៉ាងខ្លី ។<br>- ធ្វើការមួយពេលៗ ធ្វើឈប់ៗ និងធ្វើមួយ រដូវៗ ។<br><br>"កម្មករនិយោជិតមួងម្កាល ត្រូវប្រតិបត្តិនូវវិធាន និង កាតព្វកិច្ចដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ ហើយ ក៏មានសិទ្ធិដូចគ្នាដែរ លើកលែងតែកាលណាមានខសន្យាដោយឡែកពីនេះ ។" | មាន ២ មួយចំនួនតូចដែលធ្វើការបែងចែករវាងកម្មករនិយោជិតជាប់លាប់ និងកម្មករនិយោជិតមួងម្កាល:<br>- មាត្រា ២១ (សេចក្តីប្រកាសជូនដំណឹងរើសបុគ្គលិកមិនអនុវត្ត ចំពោះកម្មករនិយោជិតមួងម្កាលទេ ។<br>- មាត្រា ១៤១(៣) "...ឬសំរាប់កម្មករនិយោជិតប្រភេទខ្លះដែលធ្វើការមិនជាប់លាប់ ។" នេះបង្ហាញថា អាចជា ២ ដែលទុកលទ្ធភាពឱ្យធ្វើការផ្លាស់ប្តូរលក្ខខណ្ឌរវាងកម្មករនិយោជិតមួងម្កាល និងកម្មករនិយោជិតជាប់លាប់ ។ | ល្បង ឬជាប់លាប់ ។) **៣០/០៤, ៧៨/០៤, ៨៥/០៤** (និយោជកត្រូវផ្តល់នូវអត្ថប្រយោជន៍ និងសិទ្ធិចំពោះកម្មករនិយោជិតមួងម្កាលដូចកម្មករនិយោជិតពេញសិទ្ធិ ។)<br>**១២/០៦, ៤៤/០៦, ៤៧/០៦** (កម្មករនិយោជិតមួងម្កាល ក្លាយជាកម្មករនិយោជិតជាប់លាប់ ប្រសិនបើកម្មករនិយោជិតនោះធ្វើការ យ៉ាងហោចណាស់ ២១ថ្ងៃក្នុង១ខែ សំរាប់រយៈពេល២ខែជាប់គ្នា ។) **៤៤/០៦, ៤៧/០៦** (កម្មករនិយោជិតមួងម្កាលត្រូវទទួលបានសិទ្ធិដូចកម្មករនិយោជិតជាប់លាប់ដែរ រួមទាំងលក្ខខណ្ឌការងារអប្បរមាដែរ ។)<br>**៥៧/០៦, ៦៦/០៦** (កម្មករនិយោជិតធ្វើការ៨ ម៉ោងក្នុង១ថ្ងៃ ២៦ថ្ងៃក្នុង១ខែ សំរាប់ រយៈពេល២ខែ ជាប់ៗគ្នាត្រូវចាត់ទុកជាកម្មករជាប់លាប់) |

| | | | | |
|---|---|---|---|---|
| **ថិរវេលាសាកល្បង និង កិច្ចសន្យាសាកល្បង** | | | | |
| មាត្រា ៦៨ | កិច្ចសន្យាសាកល្បង | "ការចុះកិច្ចសន្យាសាកល្បងមិនអាចមានថិរវេលាលើសកាលបរិច្ឆេទជាចាំបាច់សំរាប់ឱ្យនិយោជកវិនិច្ឆ័យវិជ្ជាជីវៈនៃកម្មករនិយោជិត ហើយនិងសំរាប់កម្មករនិយោជិតស្គាល់យ៉ាងជាក់ច្បាស់នូវល័ក្ខខ័ណ្ឌនៃការងារដែលគេផ្តល់ឱ្យនោះឡើយ ។"<br><br>"....ការចុះកិច្ចសន្យាសាកល្បងការងារមិនអាចមានថិរវេលាលើសពីបីខែទេចំពោះនិយោជិតពីរខែចំពោះកម្មករឯកទេស និង មួយខែចំពោះកម្មករធម្មតា ។ | - ទំរង់នៃកិច្ចសន្យាសាកល្បងជាផ្នែកមួយនៃកិច្ចសន្យាការងារ ឬ ក៏កិច្ចសន្យាដាច់ឡែក ។<br>- ផលប្រយោជន៍ និង កាតព្វកិច្ចក្នុងការជួល និងការបញ្ចប់កិច្ចសន្យាការងារសាកល្បង ។<br><br>ច្បាប់ការងារកំណត់និយមន័យច្បាស់លាស់សម្រាប់និយោជិត និង កម្មករ តែមិនបានកំណត់ថា អ្នកធ្វើការប្រភេទណាទើបចាត់ទុកថាជាកម្មករឯកទេស ។ | **៩៥/០៤, ១១៣/០៤** ( កម្មករនិយោជិតសាកល្បងជាទូទៅ ត្រូវបានគេជួលឱ្យធ្វើការដោយមានកិច្ចសន្យាមានថិរវេលាកំណត់) **៩៣/០៦** ( កិច្ចសន្យាការងារសាកល្បងគឺជាកិច្ចសន្យាការងារមានថិរវេលាកំណត់)<br>**៦៩/០៤** ( រយៈពេលសាកល្បងសម្រាប់កម្មករនិយោជិតកាត់ដេរក្នុងឧស្សាហកម្មកាត់ដេរគឺ២ខែ ព្រោះពួកគាត់ត្រូវចាត់ទុកជាកម្មករនិយោជិតមានជំនាញ) |
| **ថិរវេលាធ្វើការអតិបរមាប្រចាំថ្ងៃ** | | | | |
| មាត្រា១៣៧<br><br>មាត្រា១៤០ | ថិរវេលាធ្វើការ | "ថិរវេលាអតិបរមាគឺ៤៨ម៉ោងក្នុងមួយសប្តាហ៍ ឬ ៨ម៉ោងក្នុង១ថ្ងៃ"<br>"....ថិរវេលាធ្វើការមិនត្រូវឱ្យលើសពីដប់ម៉ោងទេក្នុងមួយថ្ងៃ ។" | ថិរវេលាធ្វើការក្នុងមួយថ្ងៃអាចពន្យារហូតដល់១០ម៉ោងក្នុងមួយថ្ងៃ តែមិនច្បាស់លាស់ថាថិរវេលា១០ម៉ោងត្រូវរាប់បញ្ចូលទាំងម៉ោងការងារបន្ថែមម៉ោងដែរ ឬអត់ ។ | |
| **ភាពបត់បែននៃការចរចានៅកន្លែងធ្វើការ** | | | | |
| មាត្រា ១៣ | កិច្ចព្រមព្រៀងដែលនៅក្រោមច្បាប់ | ចែងថា "បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារនេះមានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ វៀរលែងតែមានបដិប្បញ្ញត្តិបញ្ជាក់ច្បាស់ ។ ដូច្នេះវិធាន | ក. វាមិនច្បាស់ថាតើធាតុណាមួយដែលត្រូវមោឃៈភាព ប្រសិនបើវាទាបជាងការកំណត់របស់ច្បាប់ៈ<br>- កិច្ចសន្យា/សេចក្តីសំរេច/អនុសញ្ញាទាំងមូល | **១៩/០៤, ៧៨/០៤** ( រាល់សេចក្តីសំរេចដែលធ្វើឡើងដោយភាគី, កិច្ចសន្យា ឬកិច្ចព្រមព្រៀងអនុសញ្ញារួមដែលមិន |



| | | | | |
|---|---|---|---|---|
| | | ទាំងអស់ដែលកើតឡើងដោយការសំរេចចិត្តជាឯកតោភាគីក្តី ដោយកិច្ចសន្យា ឬអនុសញ្ញាណាមួយក្តី ដែលមិនគោរពបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬដែលមិនគោរពអត្ថបទទាំងឡាយដែលណែនាំអនុវត្តច្បាប់នេះ ត្រូវទុកជាមោឃៈដោយពេញច្បាប់ ។ | - ខ នៃកិច្ចសន្យាដែលចែងទាបជាងច្បាប់<br>- វិធានជាក់លាក់ដែលបានមកពីការ អនុវត្តន៍ ខ ទាំងនោះ<br>ខ. វាមិនច្បាស់ថាតើគោលការណ៍ទូទាត់អាចអនុវត្តបាន មានន័យថា.កង្វះខាតនៃសេចក្តីសំរេចកិច្ចសន្យា ឬកិច្ចព្រមព្រៀងអាចទូទាត់ដោយច្បាប់បានដែរឬទេ ។ | ស្របនិងច្បាប់ត្រូវទុកជានិរាករណ៍ ។ នៅទីនេះ និយោជកត្រូវបង់ឱ្យទៅកម្មករនិយោជិត នូវថ្លៃពិនិត្យសុខភាពមុនពេលចូលធ្វើការ) ។ **៣០/០៤** ( កម្មករនិយោជិតម្តងម្កាលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដូចកម្មករនិយោជិតពេញសិទ្ធិដែរ ព្រោះ គ្រប់វិធានដែលចេញមកពីសេចក្តីសំរេចជាឯកតោភាគីដូចជាកិច្ចសន្យា ឬការព្រមព្រៀងដែលមិនត្រឹមត្រូវតាមច្បាប់ ឬបទបញ្ជាសំរាប់អនុវត្តត្រូវទុកជានិរាករណ៍ ។ **៦២/០៤** (IWR ដែលតំរូវឱ្យកម្មករនិយោជិតចេញប្រាក់សំរាប់ការពិនិត្យសុខភាពដោយខ្លួនឯងត្រូវទុកជាមោឃៈ ដោយមូលហេតុផ្ទុយនិងមាត្រា ២៥) ។ **៦៨/០៤** ( និយោជកបានផ្តល់ឱ្យកម្មករនិយោជិតដែលឈប់សំរាកលំហែមាតុភាពចំនួន ១៥ដុល្លាសំរាប់ថ្លៃទឹកដោះគោ ។ មាត្រា ១៣ មិនបានហាមឃាត់ក្រុមហ៊ុនក្នុងការផ្តល់អត្ថប្រយោជន៍ដែលប្រសើរជាងច្បាប់ដល់ |
| សំគាល់:<br>មាត្រា ២៥ | បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | " ប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុង ត្រូវចាត់ជាមោឃៈដោយពេញច្បាប់ក្នុងករណីដែលប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងនោះ អាចនឹងលុបចោល ឬកិតសិទ្ធិរបស់កម្មករនិយោជិត..." | សូមស្នើថា ខ ជាក់លាក់ណាមួយនៃវិធាន នេះដែលផ្ទុយច្បាប់ត្រូវមោឃៈភាពនិងទុកជា មោឃៈជាជាងមោឃៈភាពវិធានទាំងមូល ។ ហើយក៏ស្នើថាបទប្បញ្ញត្តិនីមួយៗគួរតែផ្តល់អត្ថប្រយោជន៍លើសច្បាប់ ជាជាងឱ្យវិធានទាំងមូលផ្តល់អត្ថប្រយោជន៍ | |
| សំគាល់:<br>មាត្រា ៩៨<br>( កថា.១) | កិច្ចព្រមព្រៀងការងាររួម | "... ប៉ុន្តែបទប្បញ្ញត្តិនៃអនុសញ្ញារួម មិនអាចផ្ទុយនឹងបទប្បញ្ញត្តិស្តីពីសណ្តាប់ធ្នាប់សាធារណៈនៃច្បាប់ និងបទបញ្ជាទាំងនោះទេ ។" | តើ "ការទូទាត់, ការរំលស់ ឬការដកហូត" អនុវត្តក្នុងផ្នែកផ្សេង- តើផ្នែកនេះអាចត្រូវបានប្រើដើម្បីជាជំនួយក្នុងការបកស្រាយមាត្រា ១៣? | |
| សំគាល់:<br>មាត្រា៣៦៦ | | " ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីសាមសិបមួយថ្ងៃទៅហុកសិបថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃចំពោះនិយោជកណាដែលធ្វើការទូទាត់ ការរំលស់ ឬដក | | |

| | | | | |
|---|---|---|---|---|
| | | ហួសលើប្រាក់ឈ្នួលដោយបំពានទៅលើ វិធានកំណត់ដោយមាត្រា ១២៧ មាត្រា ១២៨ និងមាត្រា ១២៩។" | | កម្មករនិយោជិតរបស់ខ្លួនឡើយ ។) **០៣/០៥** (កិច្ចព្រមព្រៀងរវាងកម្មករនិយោជិត និងនិយោជកត្រូវទុកជាមោឃៈប្រសិនបើវាផ្ទុយនិងច្បាប់ការងារ ។) **០៤/០៥** (ខ នៃកិច្ចព្រមព្រៀងមិនអាចអនុវត្តបាន ដោយសារវាផ្ដល់អត្ថប្រយោជន៍ដល់កម្មករនិយោជិតតិចជាងច្បាប់ ជាពិសេសសំរាប់ការឈប់សំរាកប្រចាំឆ្នាំ ។) **១៦/០៥** (កិច្ចព្រមព្រៀងរវាងនិយោជក និងកម្មករនិយោជិតមិនត្រូវមោឃៈភាពដោយសារ វាធ្វើឡើងដើម្បីដោះស្រាយវិវាទដែលកើតឡើងហើយ មិនមែនសំរាប់ដោះស្រាយវិវាទនៅពេលអនាគតទេ ។) **៥៦/០៦**, (បទប្បញ្ញត្តិណាមួយនៃបទបញ្ជាផ្ទៃក្នុង ដែលផ្ដល់ផលប្រយោជន៍ឱ្យកម្មករនិយោជិតតិចជាងច្បាប់ត្រូវចាត់ទុកជាមោឃៈ ។) **៦២/០៦**, (បទប្បញ្ញត្តិនៃកិច្ចសន្យាការងារដែលមានលក្ខណៈក្រោមច្បាប់ត្រូវទុកជាមោឃៈ) |

Konrad Adenauer Stiftung
សិក្ខាសាលាស្ដីពីច្បាប់ការងាររយៈពេល១០ឆ្នាំ
ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៧
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
កម្មវិធីផ្នែកច្បាប់ការងារ

| ក្រោមការត្រួតពិនិត្យរបស់អធិការការងារ | | | | |
|---|---|---|---|---|
| មាត្រា ៧១ (១១) | ការព្យួរការងារ | ព្យួរសកម្មភាពការងារពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច- ការព្យួរសកម្មភាពនេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ ។ | ឃ្លា "នៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ" មានលក្ខណៈមិនច្បាស់លាស់ ។<br>សំគាល់: ឃ្លាដូចគ្នាក៏ត្រូវបានប្រើផងដែរនៅក្នុងមាត្រា ២៧: "អធិការការងារមានសិទ្ធិសម្បទាក្នុងការត្រួតពិនិត្យភាពសមាមាត្រនេះ ។"<br>(សំដៅលើទណ្ឌកម្មខាងវិន័យ) ។ | **២១/០៣, ៨៦/០៤, ០១/០៤, ៦០/០៤** (អធិការការងារត្រូវតែបានជូនដំណឹងពីការព្យួរការងារ ដើម្បីឱ្យការព្យួរការងារនេះមានលក្ខណៈស្របច្បាប់ ។ **១០៥/០៤** (អធិការងារត្រូវតែបានជូនដំណឹងជាមុន មុនពេលដែលការព្យួរការងារចាប់ផ្ដើម ដើម្បីឱ្យការព្យួរកាងារមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។) **៨៦/០៥, ៨៩/០៥, ៥៩/០៥** (ការព្យួរការងារដែលត្រឹម ត្រូវតាមនីតិវិធីនៅពេលដែលអធិការកិច្ច ការងារផ្ដល់ការអនុញ្ញាតលើការព្យួរ), **៧២/០៥** (លក្ខខណ្ឌ២ ដើម្បី ឱ្យការព្យួរការងារដំណើរការស្របច្បាប់: ១-ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួង ២-ក្រសួងការងារត្រូវចេញលិខិតអនុញ្ញាត ។<br>ប្រសិនបើក្រសួងមិនទាន់ ឆ្លើយតបមានន័យថាក្រសួងមិនទាន់អនុញ្ញាតការព្យួរ) **៦០/០៦, ៨២/០៦, ១១៩/០៦** (ការ |

| | | | | |
|---|---|---|---|---|
| | | | | ខុសខានមិនគោរពតាមនីតិវិធីចែងក្នុងមាត្រា៧១(១១) នាំឱ្យកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលពេញពីក្រុមហ៊ុនសំរាប់កំឡុងពេលទាំងស្រុងនៃការព្យួរការងារ ។) |
| **ប្រាក់កំរៃ** | | | | |
| មាត្រា ៨១ | កាតព្វកិច្ចជូនដំណឹងមុន | | ការប្រើពាក្យ "កាតព្វកិច្ចទាំងឡាយដែលតម្រូវលើខ្លួន" — តើវាទូលំទូលាយជាង "ប្រាក់ឈ្នួល" "អត្ថប្រយោជន៍" ។ល។ | |
| មាត្រា៨៣ ក (២) និង (៣) | កំហុសធ្ងន់ | "ការមិនព្រមបើកប្រាក់ឈ្នួលឱ្យទាំងអស់ ឬ មួយភាគខ្លះ ។"<br>"ការយឺតយូរជាច្រើនលើកក្នុងការបើកប្រាក់ឈ្នួល ។ | វាមិនច្បាស់លាស់ថា "ប្រាក់ឈ្នួល" នៅទីនេះសំដៅលើបុព្វលាភ ប្រាក់បន្ទាប់បន្សំ ប្រាក់រង្វាន់ ។ល ។ | |
| មាត្រា១០៣ | និយមន័យប្រាក់ឈ្នួល | ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ :<br>- ប្រាក់ឈ្នួលសុទ្ធសាធ<br>- ប្រាក់ម៉ោងបន្ថែម<br>- កំរៃជើងសា<br>- បុព្វលាភ និងប្រាក់បំណាច់<br>- ភាគកម្មក្នុងប្រាក់ចំណេញ<br>- ប្រាក់ដែលបើកជារង្វាន់<br>- តំលៃអត្ថប្រយោជន៍ជាវត្ថុ | ប្រាក់ឈ្នួលមាននិយមន័យទូលំទូលាយ ។ ច្បាប់ការងារមិនបានបញ្ជាក់ច្បាស់ពីនិយមន័យសិទ្ធទទួលបាន ។ នៅក្នុងសិទ្ធិទទួលបាននីមួយៗខាងក្រោមឃើញមានពាក្យបច្ចេកទេសផ្សេងៗគ្នាត្រូវបានប្រើ (មើលអក្សរទ្រេត) ហើយដែលមិនស្របនិងនិយមន័យដែលមានចែងក្នុងមាត្រា ១០៣ ។<br><br>ចាំបាច់ត្រូវឱ្យនិយមន័យនៃពាក្យ: | **២៦/០៤** (កម្មករនិយោជិតបណ្តែតដែលមានគុណសម្បត្តិដូចកម្មករនិយោជិតពេញសិទ្ធិ ទទួលបានប្រាក់ឈ្នួលអប្បរមា ប្រាក់រង្វាន់ទៀងទាត់ និងប្រាក់បន្ថែមម៉ោង) ។ **៦៣/០៤** (និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតដែលឈប់សំរាកឈឺដោយមានការអនុញ្ញាត នូវប្រាក់រង្វាន់ជាធម្មតាដែលសមាមាត្រ និងចំនួនថ្ងៃដែល |



| | | | | |
|---|---|---|---|---|
| | | - វិភាជន៍គ្រួសារសំរាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់<br>- វិភាជន៍សំរាប់ការឈប់សំរាក ឬបំណាច់សំរាប់ទូទាត់ការឈប់សំរាក<br>- ចំនួនប្រាក់ដែលនិយោជកត្រូវផ្តល់ឱ្យក្នុង ពេលបាត់បង់សមត្ថភាពពលកម្ម និងក្នុងពេលលំហែមាតុភាព ។<br>មិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល :<br>- ការព្យាបាលសុខភាព<br>- វិភាជន៍គ្រួសារតាមច្បាប់<br>- សោហ៊ុយធ្វើដំណើរ<br>- អត្ថប្រយោជន៍ដែលផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិតដើម្បីសំរួលការបំពេញមុខងារ ។ | - ប្រាក់ឈ្នួលគោល (ឧ. មិនរាប់បញ្ចូលនូវបុព្វលាភ ប្រាក់បុង និងប្រាក់បន្ថែមម៉ោង)<br>- ប្រាក់ឈ្នួលធម្មតា (ឧ. រួមមានបុព្វលាភ និងប្រាក់បុង ប៉ុន្តែមិនរាប់បញ្ចូលប្រាក់បន្ថែមម៉ោងទេ ។)<br>- ប្រាក់ឈ្នួលជាមធ្យមសរុប រួមទាំងប្រាក់បន្ថែមម៉ោងផង<br>នៅពេលដែលនិយមន័យរួមមួយត្រូវបានគេអនុម័ត យើងនិងអាចពិភាក្សារកនិយមន័យសិទ្ធិដែលត្រូវទទួលបានទាំងឡាយ និងកំណត់ពីវិធីគណនា ។<br><br>នេះប្រហែលជាអាចកាត់បន្ថយជម្លោះសំខាន់ៗមួយចំនួន ។ | ពួកគេធ្វើការ) ។ **៤១/០៥** (ប្រាក់រង្វាន់អតីតភាពត្រូវរួមបញ្ចូលជាផ្នែកមួយនៃនិយមន័យច្បាប់នៃ *ប្រាក់ឈ្នួល* |
| មាត្រា១៦៨ | ការឈប់សំរាកប្រចាំឆ្នាំមាន ប្រាក់ឈ្នួល | "...ប្រាក់វិភាជន៍យ៉ាងហោចណាស់ស្មើនឹងចំនួនមធ្យមនៃប្រាក់ឈ្នួល បុព្វលាភ វិភាជន៍ អត្ថប្រយោជន៍ បំណាច់ គិតទាំង តំលៃវត្ថុដែលផ្តល់ឱ្យផងដោយមិនគិតពីបំណាច់សងសោហ៊ុយដែលកម្មករនិយោជិតបានបើករួចមក ហើយក្នុងពេលដប់ពីរខែមុនថ្ងៃឈប់សំរាក ។ ប្រាក់វិភាជន៍នេះក្នុងករណីណាក៏ដោយមិនត្រូវឱ្យតិចជាងវិភាជន៍ | ភាពខ្វះខាតថាតើប្រាក់បន្ថែមម៉ោងត្រូវបានរាប់បញ្ចូលដែលរឺទេ ។ ផ្នែក ១០៣ បញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងនិយមន័យប្រាក់ឈ្នួល ។ | |

| | | | | |
|---|---|---|---|---|
| | | ដែលកម្មករនិយោជិតត្រូវបើក កាលបើខ្លួនបានធ្វើការដោយទៀងទាត់នោះឡើយ ។" | | |
| មាត្រា១៨៣ | ការឈប់សំរាកលំហែមាតុភាព | "...ស្ត្រីមានសិទ្ធិត្រូវបានប្រាក់ ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំផង ដោយនិយោជកបើកឱ្យ ។" | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។ ផ្នែក ១០៣ រួមបញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងប្រាក់ឈ្នួល<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព ។ ផ្នែក ១០៣ រាប់បញ្ចូលប្រាក់រង្វាន់ទាំងនេះទៅក្នុងនិយមន័យប្រាក់ឈ្នួល<br><br>ពុំមាននិយមន័យច្បាស់លាស់សំរាប់ពាក្យ "ប្រាក់បន្ទាប់បន្សំ" ទាល់តែសោះ ។ ពាក្យនេះត្រូវបានប្រើ ផងដែរក្នុងមាត្រា ២៣ ដោយគោរពតាមបទបញ្ជា នៅកន្លែងធ្វើការ ("ការគណនា និងការបង់ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ") | **៤៩/០៤, ៩៦/០៦** (ប្រាក់អតីតភាព និងប្រាក់រង្វាន់ ទៀងទាត់ត្រូវបានរាប់បញ្ចូល ដើម្បីផ្តល់ឱ្យ ទៅកម្មករនិយោជិតស្ត្រី ដែលកំពុងសំរាក លំហែមាតុភាព) **២៤/០៣, ៦៨/០៤** (និយោជកគួតែផ្តល់ដល់កម្មករនិយោជិតនូវប្រាក់ឈ្នួលពេញ និងប្រាក់អតីតភាពសំរាប់រយៈពេលសំរាក លំហែមាតុភាព៣ខែហើយរក្សាទុកនូវតំណែង និងអតីតភាពការងារដល់កម្មករនិយោជិត), **៩៤/០៤** (បដិសេធការស្នើសុំតំលៃសំរាប់មាតុភាព), **២០/០៦** (ពុំមានការតំរូវ តាមច្បាប់ឱ្យផ្តល់ប្រាក់ឈ្នួល៣ខែជាមុន ដល់កម្មករនិយោជិត ដែលឈប់សំរាក លំហែមាតុភាពទេ ។) **៩៧/០៦, ៩៦/០៦, ៩៧/០៦** (សិទ្ធិទទួលបានប្រាក់ ឈ្នួលស្មើ ៥០% រួមទាំងប្រាក់បន្ទាប់បន្សំផង សំរាប់រយៈពេល លំហែមាតុភាពចំនួន ៩០ថ្ងៃមុនពេលពួក |



| | | | | |
|---|---|---|---|---|
| | | | | គេចាប់ផ្តើមឈប់សំរាក ។) **៦៦/០៦, ៩៦/០៦** (ការគណនាប្រាក់លំហែមាតុភាពត្រូវគិតដោយប្រាក់ឈ្នួល ប្រាក់រង្វាន់ និង អត្ថប្រយោជន៍ទាំងអស់ដែល កម្មការិនីទទួលបានក្នុងកំឡុង១២ខែមុន ពេលឈប់សំរាកលំហែមាតុភាពចែកនិង ១២ ។) |
| មាត្រា៨៩ (១)និង(២) | ប្រាក់បំណាច់(កិច្ចសន្យាមានថិរវេលាមិនកំណត់- "ប្រាក់បំណាច់បណ្តេញចេញ" | ផ្អែកលើថិរវេលាធ្វើការក្នុងការបង់"...ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ..." | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។ ផ្នែក ១០៣ រួមបញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងប្រាក់ឈ្នួល<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព ។ ផ្នែក ១០៣ រាប់បញ្ចូលប្រាក់រង្វាន់ទាំងនេះទៅក្នុងនិយមន័យប្រាក់ឈ្នួល<br>ពុំមានការឱ្យនិយមន័យពាក្យ "អត្ថប្រយោជន៍បន្ទាប់បន្សំ"ទាល់តែសោះ ។ ហេតុដូច្នេះហើយនាំឱ្យមានការលំបាកក្នុងការយល់ថាតើ ពាក្យនេះសំដៅលើអ្វី ។ | **០២/០៤** (ប្រសិនបើកិច្ចសន្យាត្រូវបញ្ចប់ដោយឆន្ទៈនិយោជកប្រាក់បំណាច់ដែលត្រូវផ្តល់ឱ្យទៅកម្មករនិយោជិតត្រូវរាប់បញ្ចូលនូវប្រាក់ឈ្នួលនិងអត្ថប្រយោជន៍បន្ទាប់បន្សំខ្ពស់បំផុតស្មើនឹង៦ខែ) **២៧/០៤** (មាត្រា៨៩ តំរូវថាប្រាក់បំណាច់សំរាប់ការបណ្តេញចេញត្រូវស្មើនិងប្រាក់ឈ្នួលចំនួន ១៥ថ្ងៃ និងអត្ថប្រយោជន៍បន្ទាប់បន្សំសំរាប់ការបំរើការងារនៃឆ្នាំនីមួយៗ, ដោយគោរពតាមប្រាក់ឈ្នួលអប្បរមា ឬប្រាក់ឈ្នួលសុទ្ធសាធដែលកម្មករនិយោជិតបានទទួល, ប្រាក់ឈ្នួលរួមមានប្រាក់ឈ្នួលសុទ្ធសាធ |

| | | | | |
|---|---|---|---|---|
| | | | | ឬប្រាក់បន្ថែមម៉ោង ប្រាក់រង្វាន់ និងប្រាក់បំណាច់ដោយមិនរាប់បញ្ចូលការបង់ជាពិសេសជាក់លាក់ណាមួយ) **៥៤/០៤** (ដើម្បីគណនាសំណងការខូចខាតពីការបណ្តេញចេញតាមមាត្រា៧៥, ៨៩ និង ១៦៦-១៦៧, ប្រាក់ឈ្នួលប្រចាំខែជាមធ្យមស្មើនិងប្រាក់ឈ្នួលគោលសរុបរាប់បញ្ចូលការបង់ប្រាក់បន្ថែមម៉ោង និងប្រាក់វិភាជន៍សំរាប់រយៈពេល១២ខែ មុនពេលកាលបរិច្ឆេទបណ្តេញចេញចែកនិង ១២។ ប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យមស្មើនិងប្រាក់ឈ្នួលប្រចាំខែជាមធ្យមចែកនិង២៦។ ប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យមនេះគឺប្រើសំរាប់គណនាសំណងខូចខាតសំរាប់ការបណ្តេញចេញ) **១៩/០៥** (ដោយសារនិយោជកមិនមានមូលហេតុត្រឹមត្រូវក្នុងការបញ្ឈប់កម្មករនិយោជិត និយោជកត្រូវផ្តល់នូវសំណងការខូចខាតសំរាប់ការបញ្ឈប់ និងប្រាក់បំណាច់ស្មើនិងប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងទៀតចំនួន៧ថ្ងៃ) |

Konrad Adenauer Stiftung
សិក្ខាសាលាស្តីពីច្បាប់ការងាររយៈពេល១០ឆ្នាំ
ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៧
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
កម្មវិធីផ្នែកច្បាប់ការងារ

| | | | | |
|---|---|---|---|---|
| មាត្រា៧៧ | ការជូនដំណឹងមុន( កិច្ចសន្យា មានថិរវេលាមិនកំណត់) | "...តំរូវឱ្យនិយោជកចេញប្រាក់ទូទាត់ដល់កម្មករនិយោជិតមានចំនួនស្មើគ្នានឹងប្រាក់ឈ្នួល ហើយនិងអត្ថ ប្រយោជន៍គ្រប់ប្រភេទដែលកម្មករនិយោជិតត្រូវបាន ក្នុងរយៈពេលឱ្យដំណឹងមុន ដែលគេមិនបានគោរពត្រឹមត្រូវ ។" | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។ ផ្នែក ១០៣ រួមបញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងប្រាក់ឈ្នួល<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព ។ ផ្នែក ១០៣ រាប់បញ្ចូលប្រាក់រង្វាន់ទាំងនេះទៅក្នុងនិយមន័យប្រាក់ឈ្នួល<br>ពុំមាននិយមន័យពាក្យ "អត្ថប្រយោជន៍គ្រប់ប្រភេទ" ហើយមិនច្បាស់ថាតើវាខុសពី "អត្ថប្រយោជន៍" ដែលមានចែងក្នុងមាត្រា៨៥។ | |
| មាត្រា៧៣ (កថា.៣) | ការបង់ប្រាក់ជំងឺចិត្តបញ្ចប់កិច្ចសន្យា (កិច្ចសន្យាមានកំណត់ថិរវេលា) | "...បើកសិទ្ធិឱ្យកម្មករនិយោជិតទទួលជំងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករ-និយោជិតត្រូវទទួលបាន...."<br>"...បើកសិទ្ធិឱ្យនិយោជកទទួលជំងឺចិត្តស្មើនឹងការខូចខាតរបស់ខ្លួនដែលបានផ្តល់ឱ្យកម្មករនិយោជិត ។" | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព ។<br>មាត្រា ១០៣ មិនមានប្រយោជន៍ថាតើ " ប្រាក់ឈ្នួលសុទ្ធសាធ " គួរមានន័យយ៉ាងម៉េច ។ | |
| មាត្រា១០៥ | ការធានានូវប្រាក់ឈ្នួលអប្បបរមា | "អនុសញ្ញារួមជាលាយលក្ខណអក្សរ ឬដោយមាត់ទទេ ណាដែលតំរូវឱ្យឈ្នួលទៅ កម្មករនិយោជិតដោយអត្រាទាបជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ត្រូវទុកជាមោឃៈហើយគ្មានផលអ្វីឡើយ ។" | តើ " ប្រាក់ឈ្នួលសុទ្ធសាធសំរាប់កម្មករនិយោជិត" មានន័យថាជាការបង់ពេញ ឬដោយគោរពតាមប្រាក់ឈ្នួលគោល? តើវារាប់បញ្ចូល:<br>- ប្រាក់បន្ថែមម៉ោង ឬ<br>- ប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព | |

| | | | | |
|---|---|---|---|---|
| មាត្រា១១០ | | "និយោជកត្រូវរាប់បញ្ចូលប្រាក់កំរៃជើងសា ឬប្រាក់រង្វាន់ ប្រសិនជាមានក្នុងការគិតប្រាក់ឈ្នួលនៅពេលឈប់សំរាកមានប្រាក់ឈ្នួល និងនៅពេលគិតប្រាក់បំណាច់បណ្តេញចេញក្នុងករណីដែលត្រូវដេញចោល ហើយនិងនៅពេលគិតសោហ៊ុយជំងឺចិត្ត ក្នុងករណីផ្តាច់កិច្ចសន្យាការងារ ដោយមិនប្រាប់មុន ឬករណីផ្តាច់កិច្ចសន្យាការងារនេះដោយរំលោភច្បាប់ ។ វិធីគិតប្រាក់ផ្សេងៗខាងលើនេះ ត្រូវគិតតាមប្រាក់កំរៃជើងសា ឬរង្វាន់ជាមធ្យមប្រចាំខែដែលធ្លាប់បានបើកពីមុនមកក្នុងរយៈពេលធ្វើការមិនហួសពី១២ខែ គិតមកទល់នឹងថ្ងៃចេញពីតំណែងដោយឈប់សំរាក ឬថ្ងៃឈប់ធ្វើការ ។" | ខ្វះខាតការបញ្ជាក់ពីពាក្យ "ប្រាក់ឈ្នួលសុទ្ធសាធ" ។ តើជា:<br>- ប្រាក់បន្ថែមម៉ោង ឬ<br>- ប្រាក់រង្វាន់ទ្បើងទាត់ និងប្រាក់ អតីតភាព | |
| មាត្រា១១៩ | | "...ការបើកប្រាក់ឈ្នួល ប្រាក់បំណាច់ ប្រាក់បន្ទាប់បន្សំទាំងអស់ ឬមួយផ្នែកដែលខ្លួនត្រូវបាន តាមការកំណត់របស់បទប្បញ្ញត្តិច្បាប់ បទបញ្ជាឬបទប្បញ្ញត្តិនៃកិច្ចសន្យា នោះឡើយ ។" | ការបែងចែករវាងប្រាក់ឈ្នួល, វិភាជន៍ និងអត្ថប្រយោជន៍ផ្សេងៗ, ពេលដែលមាត្រា ១០៣ យោងលើវិភាជន៍ ("វិភាជន៍សំរាប់គ្រួសារ") និងអត្ថប្រយោជន៍ផ្សេងៗ ("អត្ថប្រយោជន៍ជា វត្ថុ") ។ | |
| មាត្រា១២០ | ការកំណត់ពេលវេលា/អាជ្ញាយុកាល | "...រួមមាន: ប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់បន្ទាប់បន្សំនៃប្រាក់ឈ្នួល និងគណទេយ្យទាំងអស់..." | ការបែងចែករវាងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ អាចផ្ទុយនឹងនិយមន័យដែលផ្តល់ដោយមាត្រា១០៣ ដែល "ប្រាក់បើកជារង្វាន់" ត្រូវរាប់បញ្ចូលក្នុង "ប្រាក់ឈ្នួល" ។ | **៤១/០៥** (សិទ្ធិក្នុងការប្តឹងទាក់ទងនិងប្រាក់រង្វាន់អតីតភាពឋិតនៅក្រោមវិធានអាជ្ញាយុកាលមាត្រា ១២០) |



| | | | | |
|---|---|---|---|---|
| មាត្រា១២១ | ការធានា និងការបង់ប្រាក់គណទេយ្យ | "ប្រាក់ឈ្នួលកម្មករនិយោជិត ត្រូវបើកឱ្យមុន ប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់សំភារៈសំរាប់ប្រើប្រាស់ក្នុងសំណង់ ។" | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។ ផ្អែក ១០៣ រួមបញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងប្រាក់ឈ្នួល<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទ្បើងទាត់ និងប្រាក់អតីតភាព ។ ផ្អែក ១០៣ រាប់បញ្ចូលប្រាក់រង្វាន់ទាំងនេះទៅក្នុងនិយមន័យប្រាក់ឈ្នួល | |
| មាត្រា១២៥ | | "...ដើម្បីគិតចំនួនប្រាក់ឈ្នួលសំរាប់ការអនុវត្តន៍បទប្បញ្ញត្តិនៃមាត្រា ១២៤ ខាងលើនេះត្រូវគិត មិនត្រឹមតែប្រាក់ឈ្នួលសុទ្ធសាធទេ គឺត្រូវគិតទាំងប្រាក់ផ្សេងទៀតដូច មានចង្អុលក្នុងមាត្រា ១០៣ នៃច្បាប់នេះ..." | ធ្វើការបែងចែករវាង "ប្រាក់ឈ្នួលសុទ្ធសាធ" និងប្រភេទផ្សេងទៀតនៃប្រាក់ឈ្នួលនៅក្នុងមាត្រា ១០៣ ។ មាត្រា ១០៣ធ្វើការកំណត់ពីធាតុដែលប្រាក់ឈ្នួលគោលត្រូវបង់ ។ | |
| មាត្រា១២៨ | | "...អាចឱ្យសងវិញបាន តែតាមវិធីកាត់ប្រាក់ឈ្នួលបន្តិចម្តងៗ *ហើយក្នុងភាគប្រាក់ឈ្នួលដែលអាចផ្ទេរ ឬរឹបអូសបាន*។ ប្រាក់ដែលកាត់នេះមិនត្រូវច្រឡំនឹង*ភាគប្រាក់ឈ្នួល ដែលអាចរឹបអូសដូច*មានកំណត់ក្នុងច្បាប់ជាធរមានឡើយ ។..." | វាមិនច្បាស់ថាតើពាក្យ "ភាគឈ្នួលដែលអាចផ្ទេរ" ឬ "រឹបអូសបាន" មានន័យយ៉ាងណា?<br><br>តើវាគឺជាចំនួនប្រាក់ឈ្នួលដែលបំពេញនូវប្រាក់ឈ្នួលអប្បបរមាសំរាប់ការរស់នៅ?<br><br>ពាក្យនេះមិនមានប្រើនៅកន្លែងណាផ្សេងទៀតទេក្នុងច្បាប់ការងារ ។ | |
| មាត្រា១៣៤ | ប្រាក់ធនានុគ្រោះ | "*ប្រាក់ធនានុគ្រោះ គឺជាកំរៃដែលអតិថិជនឱ្យទៅបុគ្គលិកនៃសហគ្រាសគ្រឹះស្ថាន...*" | វាមិនច្បាស់ថា ប្រាក់ធនានុគ្រោះអាចត្រូវបានចាត់បញ្ចូលជា "ប្រាក់ដែលបើកជារង្វាន់" បើដូច្នោះវា | **១១/០៣** (ប្រាក់ធានានុគ្រោះ មិនមែនជាប្រាក់រង្វាន់ប្រចាំឆ្នាំ ប្រាក់ធានានុគ្រោះ |

| | | | | |
|---|---|---|---|---|
| | | | និងជាផ្នែកមួយនៃ "ប្រាក់ឈ្នួល" ដូចដែលមានចែងក្នុងមាត្រា ១០៣ ។<br>"gratuities"ជាភាសាខ្មែរ "ប្រាក់ដែលបើកជារង្វាន់"<br>"Perquisites" ជាភាសាខ្មែរ "ប្រាក់បន្ទាប់បន្សំ" "ប្រាក់ដែលរកបានបន្ថែមលើប្រាក់ឈ្នួលធម្មតា"<br>"Tips" ( មិនមែនជាពាក្យតែមួយជាមួយនឹងពាក្យ "ប្រាក់ដែលបើកជារង្វាន់" ) ជាភាសាខ្មែរ មិនមែនជាពាក្យប្រើប្រចាំថ្ងៃសំរាប់ "ប្រាក់ទឹកតែ" ។ ដោយសារពាក្យនេះមិនមែន ជាពាក្យសំរាប់ប្រើរាល់ថ្ងៃ សំរាប់ពាក្យ "ប្រាក់ទឹកតែ" និយមន័យប្រាក់ធានានុគ្រោះបាន កំណត់ក្នុងមាត្រា ១៣៤ ពោលគឺ "ថ្លៃសេវា" ។ | បានចាត់ទុកថាជាប្រាក់ខែដែលនិយោជកត្រូវបើកឱ្យជាសាច់ប្រាក់ពេញរៀងរាល់ខែ ) **១៨/០៤** ( កំពុងរង់ចាំប្រកាសក្រសួងចេញ មុនពេលសំរេចអំពីបញ្ហាប្រាក់ធានានុគ្រោះ ) ។ |
| មាត្រា១៦៨ | | "និយោជក ត្រូវបង់ឱ្យកម្មករនិយោជិត នៅ*ពេលមុនថ្ងៃឈប់សំរាកនូវប្រាក់វិភាជន៍ យ៉ាងហោចណាស់ស្មើនឹងចំនួនមធ្យមនៃប្រាក់ឈ្នួល បុព្វលាភ វិភាជន៍ អត្ថប្រយោជន៍ បំណាច់ គិតទាំងតំលៃវត្ថុដែលផ្តល់ឱ្យផង ដោយមិនគិតពីបំណាច់សងសោហ៊ុយដែលកម្មករនិយោជិតបានបើករួចមក...*" | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។ ផ្នែក ១០៣ រួមបញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងប្រាក់ឈ្នួល<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព ។ ផ្នែក ១០៣ រាប់បញ្ចូលប្រាក់រង្វាន់ទាំងនេះទៅក្នុងនិយមន័យប្រាក់ឈ្នួល | **០៧/០៥** ( ក្រុមហ៊ុនគណនាមិនត្រឹមត្រូវនូវប្រាក់សំណងជួសការជូនការដំណឹងសំរាប់កិច្ចសន្យាមានថិរវេលាមិនកំណត់ ពីព្រោះក្រុមហ៊ុនមិនរាប់បញ្ចូលផល-ប្រយោជន៍ផ្សេងទៀត គឺមានប្រាក់ឈ្នួល) |



| | | | | |
|---|---|---|---|---|
| មាត្រា២៧៧ | ការប្រឆាំងការរើសអើងសហជីព | "និយោជកត្រូវបានហាមឃាត់ការចាត់ទុកសហជីពចំណុះឬការចូលរួមសកម្មភាពសហជីពនៅពេល ធ្វើការសំរេចទាក់ទងនិង...*ផ្តល់អត្ថប្រយោជន៍*" | ការប្រើពាក្យផលប្រយោជន៍ហាក់ដូចជាសំដៅលើប្រាក់ដែលបើកជារង្វាន់ ឬឱកាសក្នុងការទទួលបានប្រាក់ដែលបើកជារង្វាន់ ( ឧ. ការបន្ថែមម៉ោង) ប៉ុន្តែមិនមានការបញ្ជាក់ឱ្យច្បាស់ ។<br>ពាក្យ "អត្ថប្រយោជន៍" មិនមាននិយមន័យ ។ | |
| មាត្រា៣៦០ | ប្រាក់ពិន័យ | "*...ផ្អែកលើប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ។*" | ខ្វះខាតការបញ្ជាក់ថាតើ:<br>- ត្រូវរាប់បញ្ចូលប្រាក់បន្ថែមម៉ោង ។ ផ្នែក ១០៣ រួមបញ្ចូលប្រាក់បន្ថែមម៉ោងទៅក្នុងប្រាក់ឈ្នួល<br>- ត្រូវរាប់បញ្ចូលប្រាក់រង្វាន់ទៀងទាត់ និងប្រាក់អតីតភាព ។ ផ្នែក ១០៣ រាប់បញ្ចូលប្រាក់រង្វាន់ទាំងនេះទៅក្នុងនិយមន័យប្រាក់ឈ្នួល | |
| មាត្រា៧៩ | ការឈប់សំរាក់មានប្រាក់ឈ្នួល ក្នុងអំឡុងពេលជូនដំណឹងមុន | "...*ប្រាក់ឈ្នួលពេញ* ដើម្បី ស្វែងរកការងារមួយថ្មីទៀត ។<br>ថ្ងៃឈប់នេះ ត្រូវតែគិតឈ្នួលតាម*អត្រាធម្មតានៃបៀវត្សរ*កម្មករនិយោជិត ទោះវិធីគិតប្រាក់ឈ្នួលមាន របៀបយ៉ាងណាក៏ដោយ ។ ឯប្រាក់ឈ្នួលនេះត្រូវគិតបញ្ចូលទាំង*កំរៃបន្ទាប់បន្សំ*ផង ។" | ភាពមិនច្បាស់លាស់រវាង "បង់ប្រាក់ឈ្នួលពេញ" និងពាក្យដែលប្រើនៅក្នុងកថាខ័ណ្ឌបន្ទាប់ "អត្រាធម្មតានៃបៀវត្ស" និង "ប្រាក់ឈ្នួលដែលត្រូវគិតបញ្ចូលទាំងកំរៃបន្ទាប់បន្សំ" នៅពេលដែល "ប្រាក់បើកជារង្វាន់" ត្រូវបានគិតបញ្ចូលក្នុងប្រាក់ឈ្នួលដូចចែងក្នុងមាត្រា ១០៣ ។<br>កង្វះខាតការបញ្ជាក់ថាតើអ្វីខ្លះគួររួមបញ្ចូលក្នុង "កំរៃបន្ទាប់បន្សំ" — ឬប្រាក់ឈ្នួលគិតរួមទាំងកំរៃបន្ទាប់បន្សំទាំងអស់ ។ | |

| | | | | |
|---|---|---|---|---|
| មាត្រា១១៣ | ការបង់ប្រាក់ឈ្នួល | "ប្រាក់ឈ្នួលត្រូវបើកឱ្យដោយផ្ទាល់ដៃទៅសាមីខ្លួនកម្មករនិយោជិត..." | គួរតែជាប្រាក់ឈ្នួលទាំងអស់ ។ | |
| **ការឈប់សំរាក់ដោយមានជំងឺ** | | | | |
| មាត្រា៧១ (៣) | ការឈប់សំរាកមានជំងឺ | កិច្ចសន្យាការងារ ត្រូវព្យួរដោយមូលហេតុដូចខាងក្រោមៈ...៣- អវត្តមាននៃកម្មករនិយោជិតក្នុងករណីមានជំងឺដែលមានគ្រូពេទ្យផ្លូវការ បានបញ្ជាក់ត្រឹមត្រូវ ។ ចិរវេលាអវត្តមាននោះត្រូវមានកំណត់ត្រឹមប្រាំមួយខែ ប៉ុន្តែអាចពន្យាររហូតដល់មានអ្នកជំនួស ។..." | ច្បាប់ការងារ ផ្តល់រយៈពេល៦ខែសំរាប់ការឈប់សំរាកឈឺ ។ ការឈប់សំរាកនេះហាក់ដូចជាសំដៅលើការឈប់ដោយគ្មានប្រាក់ឈ្នួល. មាត្រា៧២ចែងថា " ការព្យួរកិច្ចសន្យាការងារ នាំឱ្យប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារពោលគឺ កាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ឱ្យកម្មករនិយោជិត..." ទោះជាយ៉ាងណាសេចក្តីយោងបន្ថែមនៃសេចក្តីជូនដំណឹង ១៤/០២ ពីការរៀបចំបទបញ្ជាផ្ទៃក្នុងតំរូវឱ្យផ្តល់ប្រាក់ឈ្នួលសំរាប់ការឈប់សំរាកឈឺ ។ | **២៦/០៣** ( កិច្ចព្រមព្រៀងសំរាប់ការឈប់ឈឺមានប្រាក់ឈ្នួល), **៩៥/០៤** ( ផ្តល់ការឈប់សំរាកឈឺដោយគោរពតាមបទបញ្ជាផ្ទៃក្នុង), **១៥/០៥** ( ការផ្តល់ប្រាក់រង្វាន់ទៀងទាត់ដល់កម្មករនិយោជិតដែលបង្ហាញវេជ្ជបញ្ជា), **៦៨/០៤** ( បញ្ជាឱ្យផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតក្នុងអំឡុងពេលឈប់សំរាកឈឺ) ។ **៤៨/០៥, ៧៦/០៥** ( ការផ្តល់ប្រាក់រង្វាន់ការងារទៀងទាត់មួយចំណែក គិតទៅតាមសមាមាត្រនៃចំនួនថ្ងៃធ្វើការក្នុងមួយខែ ។ ប្រាក់រង្វាន់ទៀងទាត់អាចត្រូវបានកាត់ដោយផ្អែកលើសមាមាត្រនៃចំនួនថ្ងៃធ្វើឈប់សំរាបឈឺដោយមានការអនុញ្ញាត) ។ |
| មាត្រា១៦៦ | | "... ថ្ងៃបុណ្យតាមច្បាប់ដែលត្រូវឈប់ហើយមានប្រាក់ឈ្នួល និងការអាក់ខានធ្វើការដោយហេតុមានជំងឺនោះ មិនត្រូវរាប់ជាថ្ងៃឈប់សំរាកប្រចាំឆ្នាំមានប្រាក់ឈ្នួលនោះទេ ។" | | |
| មាត្រា១៦៩ | ការឈប់សំរាកពេលឈឺ/ការឈប់សំរាកពិសេស | "...ត្រូវរាប់បញ្ចូលទៅក្នុងរយៈពេលដែលបើកសិទ្ធិឱ្យ កម្មករនិយោជិតឈប់សំរាក ដោយមានប្រាក់ឈ្នួល តាមឆ្នាំទីមួយ១...: | <u>ការឈប់សំរាកពិសេស</u><br><u>សំគាល់</u>. មាត្រា ១៧១- ប្រសិនបើកម្មករនិយោជិតឈប់សំរាកពិសេសប៉ុន្តែមិនបានប្រើប្រាស់ថ្ងៃឈប់ | |

Konrad Adenauer Stiftung
សិក្ខាសាលាស្តីពីច្បាប់ការងាររយៈពេល១០ឆ្នាំ
ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៧
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
កម្មវិធីផ្នែកច្បាប់ការងារ

| | | | | |
|---|---|---|---|---|
| | | ...ថ្ងៃឈប់ដោយជំងឺ...ការឈប់ពិសេសដែលអនុញ្ញាតឱ្យមិនលើសពីប្រាំពីរថ្ងៃ..." | សំរាកប្រចាំឆ្នាំ និយោជកអាចកាត់កងការឈប់ពិសេសជាមួយនិងការឈប់សំរាកប្រចាំឆ្នាំ ។ វាមិនច្បាស់ថាតើកម្មករនិយោជិតនឹងទទួលបានសិទ្ធិឈប់សំរាកពិសេសត្រឹមតែ៧ថ្ងៃ ។ | |
| **ការកាត់ប្រាក់ភាគទានសហជីព** | | | | |
| មាត្រា២៨១ | ភាគទានសំរាប់សមាជិកសហជីព | "ត្រូវហាមឃាត់មិនឱ្យនិយោជកគ្រប់រូប ធ្វើការកាត់ប្រាក់ឈ្នួលនៃកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព និងហាមឃាត់មិនឱ្យនិយោជកគ្រប់រូបបង់ប្រាក់ភាគទាននេះជំនួសកម្មករនិយោជិត | មាត្រា ២៨១ និង ១២៩ ហាក់ដូចជា ប្រឆាំងគ្នា ។ | ០៣/០៣, ០៥/០៣ ( កម្មករនិយោជិតអាចអនុញ្ញាតឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនសំរាប់ភាគទានសហជីព, ការអនុញ្ញាតនេះត្រូវធ្វើជាលាយលក្ខអក្សរ ហើយអាចដកវិញនៅពេលណាក៏បាន, នៅពេលដែលកម្មករនិយោជិតអនុញ្ញាតឱ្យកាត់ប្រាក់ភាគទានសហជីព និយោជកត្រូវកាត់ចំនួននោះ ហើយបង់ឱ្យសហជីព), **១៦/០៥** ( ការកាត់ប្រាក់ឈ្នួលសំរាប់ភាគទានសហជីពក៏ប្រើសំរាប់សហជីពដែលទើបបង្កើតថ្មីផងដែ ។) **៦២/០៥, ០៥/០៦, ១៥/០៦, ៥៧/០៦, ៦២/០៦, ៩៩/០៦, ១០៦/០៦, ១១០/០៦** ( តំរូវឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីព |
| មាត្រា១២៩ | ការកាត់ប្រាក់ឈ្នួល | "...កម្មករនិយោជិត អាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក ។ ការអនុញ្ញាតនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអាចបដិសេធវិញបានគ្រប់ពេលវេលា ។" | | |

| | | | | |
|---|---|---|---|---|
| | | | | ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ប្រសិនបើមានការស្នើសុំជាលាយលក្ខអក្សរពីនិយោជិតនោះ) |
| **ឋានៈសហជីព** | | | | |
| មាត្រា២៧៧ | សហជីពដែលមានភាពជាតំណាងបំផុត | | វាមិនច្បាស់ថាតើអាចមានសហជីពលើសពី ២ នៅកន្លែងធ្វើការមួយដែរទេ- មិនមានការកំណត់ច្បាស់លាស់ណាមួយទេ ប៉ុន្តែមានតែសហជីព២ ប៉ុណ្ណោះដែលអាចមាន "ភាពជាតំណាង"។ វាក៏មិនច្បាស់ដែរថាតើអ្វីជាអត្ថប្រយោជន៍នៃភាពជាតំណាង។ | |
| សំគាល់: មាត្រា ៩៩ | វិសាលភាពនៃការអនុវត្តន៍កិច្ចព្រមព្រៀងអនុសញ្ញារួម | " តាមសេចក្ដីសុំរបស់អង្គការខាងវិជ្ជាជីវៈនៃកម្មករនិយោជិត ឬនិយោជកដែលជាតំណាងនៅក្នុងដែនអនុវត្ត ពាក់ព័ន្ធ ឬតាមការផ្ដើមគំនិតរបស់ខ្លួនផ្ទាល់ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារក្រោយដែលបានស្នើយោបល់គណៈកម្មការប្រឹក្សាការងាររួច អាចសំរេះសំរួលឱ្យប្រើបទប្បញ្ញត្តិខ្លះ ឬទាំងស្រុងនៃអនុសញ្ញារួមចំពោះ និយោជក និងកម្មករនិយោជិតដែលស្ថិតនៅក្នុងផ្នែកវិជ្ជាជីវៈ និងដែនអនុវត្តអនុសញ្ញានោះ។ | | |



| | | | | |
|---|---|---|---|---|
| **ពាក្យច្បាប់** | | | | |
| មាត្រា១៣, ៦៥, ៧២ និង៧៦ ជាឧទាហរណ៍ | | | មិនមានការបញ្ជាក់ឱ្យបានច្បាស់ថាតើពាក្យខាងក្រោមនេះមានន័យដូច ឬខុសគ្នា:<br>- Provision- បទប្បញ្ញត្តិ<br>- clause- ខ<br>- rule- វិធាន<br>- regulation- បទបញ្ជាប្រតិបត្តិ<br>- article (of a labour contract) ប្រការ | |